# សុខភាពសាធារណៈ

# ជំងឺគ្រុនផ្តាសាយ H1N1 (ផ្តាសាយជ្រូក)

Massachusetts Department of Public Health

**តើអ្វីគឺជាជំងឺគ្រុនផ្តាសាយ H1N1?**

ជំងឺគ្រុនផ្តាសាយ (Flu) គឺជាជំងឺប្រព័ន្ធដង្ហើមរបស់រាងកាយ រួមមាន ច្រមុះ, បំពង់ក និង សួត។ Flu គឺជាពាក្យកាត់នៃ "Influenza"។ ជំងឺគ្រុនផ្តាសាយ H1N1 បង្កឡើងដោយមេរោគថ្មីមួយដែលបានស្គាល់ដំបូងក្នុងខែមេសា ២០០៩ និង ត្រូវបានហៅថា "ជំងឺគ្រុនផ្តាសាយជ្រូក"។ ជំងឺគ្រុនផ្តាសាយ H1N1 ឆ្លងរាលដាលយ៉ាងលឿនទៅតំបន់ជាច្រើននៃពិភពលោក ហើយឥឡូវគឺជា "ជំងឺឆ្លងរាលដាលពាសពេញទ្វីប" ឬ ជំងឺឆ្លងរាលដាលទូទាំងពិភពលោក។ ជំងឺគ្រុនផ្តាសាយ H1N1 មិនដូចគ្នានឹងជំងឺគ្រុនផ្តាសាយជ្រូក ដែលជាមេរោគមួយដែលសត្វជ្រូកអាចទទួលឡើយ។ វាក៏មិនដូចនឹងជំងឺគ្រុនផ្តាសាយ "តាមរដូវ" ដែលកើតឡើងរៀងរាល់ឆ្នាំ ក្នុងអំឡុងសិសិររដូវ និង ដើមនិទាឃរដូវនោះដែរ។ ប៉ុន្តែ ជំងឺគ្រុនផ្តាសាយ H1N1 បង្ករោគសញ្ញាដែលស្រដៀងនឹងជំងឺគ្រុនផ្តាសាយតាមរដូវ, ឆ្លងរាលដាលដូចនឹងជំងឺគ្រុនផ្តាសាយតាមរដូវ និង អាចបង្ការបានដូចជំងឺគ្រុនផ្តាសាយតាមរដូវដែរ។

**តើអ្វីគឺជារោគសញ្ញានៃជំងឺគ្រុនផ្តាសាយ H1N1?**

រោគសញ្ញានៃជំងឺគ្រុនផ្តាសាយ H1N1 ស្រដៀងគ្នាណាស់នឹងរោគសញ្ញានៃជំងឺគ្រុនផ្តាសាយតាមរដូវ។ រោគសញ្ញាទូទៅបំផុតមាន គ្រុនក្តៅ, ក្អក និង ឈឺក។ រោគសញ្ញាក៏អាចរួមមានការឈឺខ្លួន, ឈឺក្បាល, រងារញាក់, ហៀរសំបោរ និង មានអារម្មណ៍អស់កម្លាំងដែរ។ មនុស្សមួយចំនួនក៏មានជំងឺរាគ និង ក្អួតផងដែរ។ រោគសញ្ញាទាំងនេះអូសបន្លាយពីពីរបីថ្ងៃដល់ទៅមួយសប្តាហ៍ ឬ ច្រើនជាងនេះ។

**តើជំងឺគ្រុនផ្តាសាយ H1N1 ធ្ងន់ធ្ងរដែរឬទេ?**

ការឈឺដោយជំងឺគ្រុនផ្តាសាយ H1N1 អាចមធ្យមទៅធ្ងន់ធ្ងរ។ ខណៈដែលមនុស្សភាគច្រើនឈឺដោយសារជំងឺគ្រុនផ្តាសាយ H1N1 ធូរស្បើយដោយមិនត្រូវការការព្យាបាលបែបវេជ្ជសាស្ត្រ មនុស្សមួយចំនួនមានជំងឺនេះធ្ងន់ធ្ងរ និង បានទទួលមរណភាព។ ដូចនឹងជំងឺគ្រុនផ្តាសាយតាមរដូវដែរ មនុស្សមួយចំនួនមានហានិភ័យខ្ពស់ចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរ នៅពេលពួកគេឆ្លងជំងឺគ្រុនផ្តាសាយ H1N1។ អ្នកទាំងនោះរួមមានស្រ្តីមានគភ៌, ទារក និង មនុស្សដែលមានស្ថានភាពសុខភាពដូចជាជំងឺហឺត, ទឹកនោមផ្អែម, ជំងឺបេះដូង, ជំងឺតម្រងនោម, ស្ថានភាពសាច់ដុំ និង សរសៃប្រសាទដែលប៉ះពាល់ដល់ផ្លូវដង្ហើមរបស់ពួកគេ និង ប្រព័ន្ធស៊ាំនឹងជំងឺដែលទន់ខ្សោយ។

**តើជំងឺគ្រុនផ្តាសាយ H1N1 ឆ្លងរាលដាលដូចម្តេច?**

មេរោគគ្រុនផ្តាសាយស្ថិតនៅក្នុងជាតិទឹករសើម (ដំណក់ទឹកមាត់ និង សំបោរ ឬ ស្លេស្ម) ដែលចេញពីច្រមុះ និង មាត់របស់នរណាម្នាក់ដែលក្អក ឬ កណ្តាស់។ ប្រសិនបើអ្នកនៅជិតល្មមនឹងមនុស្សដែលមានជំងឺគ្រុនផ្តាសាយ (៣ - ៦ ហ្វីត) នៅពេលពួកគេក្អក ឬ កណ្តាស់ អ្នកអាចដកដង្ហើមចូលមេរោគនោះ និង អាចឈឺ។ រោគសញ្ញាគ្រុនផ្តាសាយចាប់ផ្តើម ១ - ៤ ថ្ងៃ (ជាធម្មតា ២ ថ្ងៃ) បន្ទាប់ពីមនុស្សនោះដកដង្ហើមចូលមេរោគនោះ។

ជំងឺគ្រុនផ្តាសាយឆ្លងរាលដាល<u>យ៉ាងងាយស្រួល</u>ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ មេរោគនោះក៏អាចរស់នៅក្នុងរយៈពេលខ្លីលើរបស់ដែលអ្នកប៉ះ ដូចជាដៃទ្វារ, ទូរស័ព្ទ និង ប្រដាប់ប្រដាក្មេងលេងផងដែរ។ បន្ទាប់ពីអ្នកប៉ះវត្ថុទាំងនេះ អ្នកអាចឆ្លងមេរោគនោះ នៅពេលអ្នកប៉ះមាត់, ច្រមុះ ឬ ភ្នែករបស់អ្នក។ ទោះជាយ៉ាងនេះក្តី នៅពេលដំណក់ទឹករសើមលើប្រភេទនៃវត្ថុទាំងនេះស្ងួត មេរោគនោះមិនអាចបង្កការឆ្លងឡើយ។ មនុស្សពេញវ័យដែលមានជំងឺគ្រុនផ្តាសាយ H1N1 អាចចម្លងវាពីប្រហែលមួយថ្ងៃមុនរោគសញ្ញានោះលេចឡើង ទៅប្រហែល ១ សប្តាហ៍បន្ទាប់ពីនោះ។ ក្មេងអាចចម្លងជំងឺគ្រុនផ្តាសាយយូរជាងនេះបន្ទាប់ពីពួកគេឈឺ។

**តើជំងឺគ្រុនផ្តាសាយ H1N1 អាចព្យាបាលបានដែរឬទេ?**

មានថ្នាំដែលវេជ្ជបណ្ឌិតរបស់អ្នកអាចចេញវេជ្ជបញ្ជាឲ្យអ្នកដើម្បីព្យាបាលជំងឺគ្រុនផ្តាសាយ H1N1។ ថ្នាំទាំងនោះមានប្រសិទ្ធិភាពខ្ពស់ ប្រសិនបើបានប្រើភ្លាមៗបន្ទាប់ពីរោគសញ្ញាចាប់ផ្តើមកើតឡើង។ វេជ្ជបណ្ឌិតរបស់អ្នកអាចសម្រេចថាតើអ្នកត្រូវការការព្យាបាលដែរឬទេ។

មនុស្សដែលឈឺដោយសារប្រភេទណាមួយនៃជំងឺគ្រុនផ្តាសាយត្រូវប្រាកដថាពិសារវត្ថុរាវឲ្យបានគ្រប់គ្រាន់, សម្រាកឲ្យបានគ្រប់គ្រាន់, បរិភោគអាហារដែលមានសុខភាពល្អ, លាងសម្អាតដៃរបស់ពួកគេជាប្រចាំ និង ស្នាក់នៅផ្ទះដើម្បីជៀសវាងការចម្លងជំងឺគ្រុនផ្តាសាយទៅមនុស្សដទៃ។ ថ្នាំបន្ធូរការឈឺចាប់ដែលមានលក់នៅតាមហាងអាចជួយមនុស្សដែលមានជំងឺគ្រុនផ្តាសាយឲ្យមានអារម្មណ៍សុខស្រួលច្រើន។ កូនក្មេង និង ក្មេងជំទង់ដែលមានជំងឺគ្រុនផ្តាសាយ<u>មិនត្រូវ</u>ប្រើថ្នាំ Aspirin ឡើយ ពីព្រោះជំងឺកម្រ ប៉ុន្តែធ្ងន់ធ្ងរមួយហៅថា Reye syndrome អាចកើតឡើង។

**តើមានថ្នាំបង្ការជំងឺគ្រុនផ្តាសាយ H1N1 ដែរឬទេ?**

បាទ/ចាស។ ថ្នាំបង្ការជួយឲ្យរាងកាយរបស់អ្នកការពារខ្លួនឯងប្រឆាំងនឹងជំងឺ។ ថ្នាំបង្ការ H1N1 មានពីរប្រភេទដើម្បីការពារប្រឆាំងនឹងជំងឺគ្រុនផ្តាសាយ H1N1។ ប្រភេទមួយគឺ "ថ្នាំចាក់" តាមម្ជុល ជាធម្មតាចាក់តាមដៃ។ ប្រភេទមួយទៀតគឺ "បាញ់តាមច្រមុះ" (ថ្នាំដែលបាញ់ចូលតាមច្រមុះ)។ មនុស្សដែលមានអាយុ ១០ ឆ្នាំ និង លើសពីនេះ នឹងត្រូវការថ្នាំបង្ការមួយដុស។ ក្មេងភាគច្រើនដែលមានអាយុក្រោម ១០ ឆ្នាំ នឹងត្រូវការថ្នាំបង្ការ H1N1 ពីរដុសដាច់ពីគ្នា ៣-៤ សប្តាហ៍។ ការទទួលថ្នាំបង្ការជំងឺគ្រុនផ្តាសាយនឹងមិនធ្វើឲ្យអ្នកកើតជំងឺគ្រុនផ្តាសាយ ឬ ប្រភេទនៃជំងឺដទៃទៀតឡើយ។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នកថាថ្នាំបង្ការ H1N1 ប្រភេទណាមួយដែលល្អបំផុតសម្រាប់អ្នក និង គ្រួសាររបស់អ្នក។

**តើនរណាគួរទទួលថ្នាំបង្ការជំងឺគ្រុនផ្តាសាយ H1N1?**

ក្រុមជាកលាក់មួយចំនួនគួរទទួលថ្នាំបង្ការ H1N1 នៅពេលមានវាៈ ស្ត្រីមានគភ៌; មនុស្សដែលរស់នៅជាមួយ ឬ ផ្តល់ការថែទាំទារកអាយុក្រោម ៦ ខែ (ឧទា. ឪពុកម្តាយ, បងប្អូនបង្កើត និង ឧបដ្ឋាកថែទាំពេលថ្ងៃ); បុគ្គលិកថែទាំសុខភាព និង ផ្តល់សេវាសុខភាពសង្គ្រោះបន្ទាន់; មនុស្សមានអាយុ ៦ ខែ ដល់ ២៤ ឆ្នាំ; និង មនុស្សមានអាយុ ២៥ ទៅ ៦៤ ឆ្នាំដែលមានស្ថានភាពសុខភាពអាចធ្វើឲ្យពួកគេមានហានិភ័យខ្ពស់ចំពោះភាពលំបាកដែលទាក់ទងនឹងជំងឺគ្រុនផ្តាសាយ។ បន្ទាប់ពីក្រុមទាំងនេះ វាត្រូវបានរំពឹងថានឹងមានថ្នាំបង្ការជំងឺគ្រុនផ្តាសាយ H1N1 គ្រប់គ្រាន់សម្រាប់នរណាម្នាក់ដែលជ្រើសរើសទទួលថ្នាំបង្ការ។ សូមកត់សម្គាល់ថាក្រុមដែលបានរាយខាងលើអាចផ្លាស់ប្តូរអាស្រ័យលើភាពមាននៃថ្នាំបង្ការ។ *សម្គាល់៖ ការសិក្សាថ្មីៗបង្ហាញថាហានិភ័យចំពោះការឆ្លងមេរោគក្នុងចំណោមមនុស្សអាយុលើស ៦៥ ឆ្នាំ មានតិចជាងក្រុមមនុស្សវ័យក្មេង។*

**តើខ្ញុំដឹងដូចម្តេចថាតើខ្ញុំមានជំងឺគ្រុនផ្តាសាយ H1N1 ដែរឬទេ?**

ប្រសិនបើអ្នកមានរោគសញ្ញាជំងឺគ្រុនផ្តាសាយ វាអាចជាជំងឺគ្រុនផ្តាសាយតាមរដូវ ឬ H1N1។ ប្រសិនបើអ្នកគិតថាអ្នកមានជំងឺគ្រុនផ្តាសាយ សូមស្នាក់នៅផ្ទះកុំទៅធ្វើការ ឬ ទៅសាលា និង ជៀសវាងទាក់ទងជាមួយអ្នកដទៃ ដូច្នេះអ្នកនឹងមិនចម្លងមេរោគនេះឡើយ។ ប្រសិនបើអ្នកគិតថាអ្នកអាចមានជំងឺគ្រុនផ្តាសាយ ហើយអ្នកត្រូវការទៅជួបវេជ្ជបណ្ឌិត សូមហៅទូរស័ព្ទជាមុន ហើយឲ្យពួកគេដឹងថាអ្នកអាចមានជំងឺគ្រុនផ្តាសាយ។ តាមវិធីនេះ ការិយាល័យវេជ្ជបណ្ឌិតរបស់អ្នកអាចអនុវត្តជំហានដែលអាចជៀសវាងការឆ្លងរាលដាលនៃជំងឺគ្រុនផ្តាសាយដល់អ្នកដទៃ។ វេជ្ជបណ្ឌិតអាចឲ្យយោបល់អ្នកធ្វើតេស្តរកជំងឺគ្រុនផ្តាសាយ។

**តើខ្ញុំការពារខ្លួនខ្ញុំពីការឈឺជំងឺគ្រុនផ្តាសាយ H1N1 ដូចម្តេច?**

- ទទួលថ្នាំបង្ការនៅពេលមាន ជាពិសេស ប្រសិនបើអ្នកមានស្ថានភាពសុខភាពដែលអាចបង្កភាពលំបាកផ្នែកសុខភាពដោយសារជំងឺគ្រុនផ្តាសាយកាន់តែច្រើន។
- លាងសម្អាតដៃរបស់អ្នកឲ្យបានញឹកញាប់ជាមួយសាប៊ូ និង ទឹក ឬ ប្រើជែលត្រដុសដៃមានជាតិអាល់កុល។
- ក្អក ឬ កណ្តាស់ទៅក្នុងក្រដាសជូត ឬ ទៅក្នុងកែងដៃរបស់អ្នក ប្រសិនបើអ្នកមិនមានក្រដាសជូត។ សូមបោះក្រដាសជូតនោះទៅក្នុងធុងសំរាម និង លាងសម្អាតដៃរបស់អ្នក។ តែងលាងសម្អាតដៃរបស់អ្នកជានិច្ច មុនពេលអ្នកប៉ះភ្នែក, ច្រមុះ ឬ មាត់របស់អ្នក។

- ប្រើប្រដាប់សម្អាតក្នុងគ្រួសារធម្មតាដើម្បីសម្អាតផ្ទៃដែលអាចមានមេរោគគ្រុនផ្តាសាយលើនោះដូចជាដៃទ្វា, ទូរស័ព្ទ, រ៉ូប៊ីណេ និង ប្រដាប់ប្រដាក្មេងលេង។
- ស្នាក់នៅផ្ទះកុំទៅធ្វើការ និង ទៅសាលា ប្រសិនបើអ្នកឈឺដោយសារជំងឺដូចជំងឺគ្រុនផ្តាសាយ និង ជៀសវាងទាក់ទងជាមួយមនុស្សដទៃ ដូច្នេះមេរោគនេះមិនអាចឆ្លងរាលដាលឡើយ។ សូមស្នាក់នៅផ្ទះរហូតដល់អ្នកលែងមានគ្រុនក្តៅ ក្នុងពេលយ៉ាងតិច ២៤ ម៉ោងបន្ទាប់ពីអ្នកប្រើថ្នាំបន្ថយគ្រុនក្តៅចុងក្រោយ (ដូចជា Tylenol, Advil ឬ Motrin)។ ចំពោះមនុស្សជាច្រើន ការណ៍នេះមានន័យថាត្រូវស្នាក់នៅផ្ទះក្នុងពេលប្រហែលបួនថ្ងៃ។

**តើខ្ញុំអាចថែទាំអ្នកដែលឈឺជំងឺគ្រុនផ្តាសាយ H1N1 ដូចម្តេច?**

*ជំងឺគ្រុនផ្តាសាយ៖ អ្វីដែលអ្នកអាចធ្វើ - ការថែទាំមនុស្សនៅផ្ទះ* គឺជាកូនសៀវភៅមានជា ៩ ភាសា ដែលផ្តល់ជូនអ្នកនូវព័ត៌មានជាច្រើនដើម្បីជួយអ្នកថែទាំអ្នកមានជំងឺគ្រុនផ្តាសាយនៅផ្ទះរបស់ពួកគេ។ វីដេអូក៏មានជាភាសាអង់គ្លេស និង អេស្ប៉ាញផងដែរ។ ព័ត៌មាន *ជំងឺគ្រុនផ្តាសាយ៖ អ្វីដែលអ្នកអាចធ្វើ* អាចរកបានតាម៖ www.mass.gov/flu។

## តើខ្ញុំអាចទទួលព័ត៌មានបន្ថែមពីកន្លែងណា?

- Mass 2-1-1 ផ្តល់ព័ត៌មានអំពីជំងឺគ្រុនផ្តាសាយសម្រាប់សាធារណជនទូទៅ៖ ហៅទូរស័ព្ទទៅ 211 ឬ 1-877-211-MASS (6277)។ មានសេវាបកប្រែជាភាសាជាច្រើន។
- ហៅទូរស័ព្ទទៅវេជ្ជបណ្ឌិត, គិលានុប្បដ្ឋាយិកា ឬ មន្ទីរព្យាបាល ឬ ក្រុមប្រឹក្សាសុខភាពក្នុងស្រុករបស់អ្នក
- ហៅទូរស័ព្ទទៅក្រសួងសុខាភិបាលសាធារណៈនៃរដ្ឋម៉ាសាជូសេត ផ្នែកកម្មវិធីថ្នាំបង្ការ តាមលេខ៖ (617) 983-6800 ឬ លេខឥតបង់ប្រាក់តាម (888) 658-2850
- វិបសៃក្រសួងសុខាភិបាលសាធារណៈនៃរដ្ឋម៉ាសាជូសេតតាម mass.gov/flu
- មជ្ឈមណ្ឌលគ្រប់គ្រង និង បង្ការជំងឺ (CDC) តាម៖ www.cdc.gov/flu

ចំពោះព័ត៌មានអំពីមន្ទីរព្យាបាលជំងឺគ្រុនផ្តាសាយ សូមចូលមើលវិបសៃរកមន្ទីរព្យាបាលជំងឺគ្រុនផ្តាសាយសាធារណៈ MassPRO (MassPRO Public Flu Clinic Finder) តាម៖ http://flu.masspro.org/

បានធ្វើបច្ចុប្បន្នភាពថ្ងៃទី ៦ វិច្ឆិកា ២០០៩